**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

លេខ ១០៥ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០០

## ប្រកាស
## ស្តីពី
## ចំណាត់ថ្នាក់សណ្ឋាគារ

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

**សម្រេច**

**ប្រការ ១ :** ចំណាត់ថ្នាក់សណ្ឋាគារ គឺសំដៅបញ្ជាក់អំពីកម្រិតគុណភាពជាក់លាក់នៃសេវាកម្ម សម្ភារៈ និងគ្រឿងបំពាក់ ដែលជាកម្មសិទ្ធិរបស់សណ្ឋាគារ អោយបានសមស្របតាមនិយាមអន្តរជាតិ ។

Downloaded from http://www.khmerlaws.com

**ប្រការ ២ :** សេចក្តីសម្រេចផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ គឺជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។ ការវាយតម្លៃផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ - គឺត្រូវធ្វើឡើងតែចំពោះមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅដែលមានលក្ខណៈជាសណ្ឋាគារតែប៉ុណ្ណោះ ។

**ប្រការ ៣ :** សណ្ឋាគារទាំងអស់ត្រូវមានចំណាត់ថ្នាក់ ។ ចំណាត់ថ្នាក់សណ្ឋាគារត្រូវមានការស្នើសុំ និងបំពេញបែបបទដោយអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ។

**ប្រការ ៤ :** ចំណាត់ថ្នាក់សណ្ឋាគារ ត្រូវបានកំណត់ចាប់ពីកម្រិតអប្បបរិមាថ្នាក់ផ្កាយមួយរហូតដល់អតិបរិមាថ្នាក់ផ្កាយប្រាំ តាមប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ ។

**ប្រការ ៥ :** គោលការណ៍សំខាន់ៗ សម្រាប់វិនិច្ឆ័យផ្តល់ចំណាត់ថ្នាក់សណ្ឋាគារមាន :

- ទីតាំងស្ថាបត្យកម្ម និងទិដ្ឋភាពទូទៅ ដោយរាប់បញ្ចូលទាំងគុណភាព និងលក្ខខណ្ឌផ្នែកខាងក្រៅអគារ ទស្សនីយភាព ទីសាធារណៈក្នុងអគារ និងបន្ទប់ភ្ញៀវ
- ការបំពាក់សម្ភារៈបរិក្ខារ ដោយរាប់បញ្ចូលផ្នែកម្រាល និងជញ្ជាំង វាំងនន អគ្គិសនីបំភ្លឺ ប្រព័ន្ធប្រើប្រាស់អគ្គិសនី គ្រឿងសង្ហារឹម ព័ត៌មាន និងទូរគមនាគមន៍
- អនាម័យ និងការថែទាំ ដោយរាប់បញ្ចូលបន្ទប់ភ្ញៀវ បន្ទប់ទឹក កន្លែងសាធារណៈ កន្លែងកម្សាន្ត
- សេវា និងគុណភាពសេវា ដោយរាប់បញ្ចូលឯកសណ្ឋាន អាកប្បកិរិយារបស់បុគ្គលិកចំពោះភ្ញៀវ ការគ្រប់គ្រង និងទំនាក់ទំនងរវាងបុគ្គលិកជាមួយ និងភ្ញៀវ សុវត្ថិភាព និងសន្តិសុខភ្ញៀវ
- សេវាកម្មផ្តល់ម្ហូបអាហារ ដោយប្រើប្រាស់ផលិតផលក្នុងស្រុកដែលមានគុណភាព និងមានអនាម័យ រាប់បញ្ចូលភោជនីយដ្ឋាន ការបំរើអាហារដល់បន្ទប់ គុណភាពម្ហូបអាហារ ចំនួនមុខម្ហូប ការរៀបចំតុ និងពិធីផ្សេងៗ
- ភ្លេងប្រពៃណី និងរបាំបុរាណខ្មែរ ។

**ប្រការ ៦ :** ការដាក់ពាក្យសុំចំណាត់ថ្នាក់សណ្ឋាគារ ត្រូវភ្ជាប់មកជាមួយនូវអាជ្ញាបណ្ណទេសចរណ៍ និងឯកសារមួយចំនួនតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍ ព្រមទាំងត្រូវបង់ថ្លៃសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃរៀបចំចំណាត់ថ្នាក់សណ្ឋាគារ ដូចខាងក្រោម :

| | | |
|---|---|---|
| - ចំណាត់ថ្នាក់ផ្កាយប្រាំ | ១.២០០.០០០ | រៀល (មួយលានពីរសែនរៀល) |
| - ចំណាត់ថ្នាក់ផ្កាយបួន | ១.០០០.០០០ | រៀល (មួយលានរៀល) |
| - ចំណាត់ថ្នាក់ផ្កាយបី | ៨០០.០០០ | រៀល (ប្រាំបីរយពាន់រៀល) |
| - ចំណាត់ថ្នាក់ផ្កាយពីរ | ៦០០.០០០ | រៀល (ប្រាំមួយរយពាន់រៀល) |
| - ចំណាត់ថ្នាក់ផ្កាយមួយ | ៤០០.០០០ | រៀល (បួនរយពាន់រៀល) |
| - សណ្ឋាគារមិនជាប់ចំណាត់ថ្នាក់ | ២០០.០០០ | រៀល (ពីររយពាន់រៀល) |

**ប្រការ ៧ :** គំរូស្លាកសញ្ញា និងសញ្ញាចំណាត់ថ្នាក់សណ្ឋាគារត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍ រីឯថ្លៃស្លាកសញ្ញាចំណាត់ថ្នាក់ ជាបន្ទុករបស់អ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ។

Downloaded from http://www.khmerlaws.com

**ប្រការ ៨ :** ចំណាត់ថ្នាក់សណ្ឋាគារមានសុពលភាពរយៈពេលពីរឆ្នាំ ។ មុនពេលផុតសុពលភាពយ៉ាងតិច ៩០ថ្ងៃនៃថ្ងៃធ្វើការ អ្នកទទួលខុសត្រូវសណ្ឋាគារត្រូវដាក់ពាក្យសុំការវាយតម្លៃចាត់ថ្នាក់សណ្ឋាគារឡើងវិញ។

- ចំណាត់ថ្នាក់សណ្ឋាគារនិមួយៗ អាចត្រូវតម្លើងថ្នាក់ បញ្ចុះថ្នាក់ ព្យួរ ឬ បដិសេធក្នុងរយៈពេលសុពលភាព នៃចំណាត់ថ្នាក់ ។

**ប្រការ ៩ :** ការពិនិត្យ និងវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារអាចធ្វើលើសពីមួយដង ( មិនលើសពីបីដងក្នុងវគ្គនីមួយៗ) ទៅតាមសំណូមពរចាំបាច់របស់ ម្ចាស់ រឺអ្នកទទួលខុសត្រូវគ្រប់គ្រងសណ្ឋាគារ ដែលត្រូវបង់ថ្លៃការងារពិនិត្យ និងវាយតម្លៃបន្ថែមនិមួយៗ ស្មើនឹង ៧០% នៃថ្លៃកម្រិតរៀបចំចំណាត់ថ្នាក់សណ្ឋាគារដូចមានចែងក្នុងប្រការ ៦។

**ប្រការ ១០ :** ការប្រើប្រាស់ចំណាត់ថ្នាក់សណ្ឋាគារ ហួសសុពលភាព ឬការផ្សព្វផ្សាយអំពីចំណាត់ថ្នាក់សណ្ឋាគារ ដែលមិនបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ត្រូវចាត់ថាខុសច្បាប់ និងត្រូវពិន័យអន្តរការណ៍ តាមមាត្រា ៤៨ នៃច្បាប់ស្តីពីទេសចរណ៍ ។

**ប្រការ ១១:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២ :** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួង ទេសចរណ៍

**ថោង ខុន**

**__កន្លែងទទួល:__**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត "ដើម្បីមុខការ"
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសណ្ឋាគារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com